GOVERNMENT OF WESTERN AUSTRALIA

WESTERN AUSTRALIAN **Government Schools**

**Dream Discover Learn**

# សាលារដ្ឋទាំងឡាយនៅក្នុងរដ្ឋ Western Australia ជួយគាំទ្រសិស្សអន្តរជាតិដើម្បីឲ្យសម្រេចបាននូវជោគជ័យផ្នែកសិក្សា ដោយមានផ្លូវដើរមួយចំនួនផ្សេងៗគ្នានិងកម្មវិធីសិក្សាដែលទទួលស្គាល់ជាអន្តរជាតិ។

**សាលារៀនរបស់យើងផ្តល់មជ្ឈដ្ឋានថែទាំនិងរាប់បញ្ចូលដើម្បីជួយសិស្សនីមួយៗឲ្យទទួលបានសក្តានុពលរបស់គេ។ ចូលរួមជាមួយសិស្សរាប់ពាន់នាក់មកពីជុំវិញពិភពលោក ដែលបានជ្រើសយករដ្ឋ Western Australia ជាគោលដៅនៃការសិក្សារបស់គេ។**

## បែបបទរស់នៅនៃក្រុង Perth

Perth ដែលជាធានីនៃរដ្ឋ Western Australia គឺជាក្រុងពហុវប្បធម៌ដែលមានសុវត្ថិភាពនិងភាពរស់រវើក។ ប្រជាពលរដ្ឋមានភាពស្រស់ស្រាយរាក់ទាក់ និងមានអ្វីៗជាច្រើនរាប់មិនអស់ដើម្បីធ្វើ។ ប្រព័ន្ធយានជំនិះសាធារណៈមានភាពសាមញ្ញដើម្បីធ្វើដំណើរ និងមានសុវត្ថិភាពសម្រាប់សិស្សប្រើប្រាស់។

ទីក្រុងនេះផ្តល់បែបបទរស់នៅដែលធ្វើឲ្យមានអារម្មណ៍ធូរស្រាលជាមួយនឹងទិដ្ឋភាពសិល្បៈលូតលាស់ប្រសើរឧត្តម សកម្មភាពនៅទីវាល និងការចេញចូលដ៏ងាយស្រួលទៅកាន់ទីកន្លែងមានសោភ័ណភាពធម្មជាតិដ៏អស្ចារ្យរបស់រដ្ឋ Western Australia ធ្វើឲ្យទីក្រុងនេះជាទីកន្លែងល្អប្រសើរសម្រាប់សិស្សអន្តរជាតិ។

## ប្រព័ន្ធអប់រំនិងការសិក្សាថ្នាក់អន្តរជាតិ

សាលារៀនរបស់យើងផ្តល់កម្មវិធីសិក្សាដែលទទួលស្គាល់ជាអន្តរជាតិ ដោយមានការយកចិត្តទុកដាក់មួយលើការគិតគូរស៊ីជម្រៅ ភាពច្នៃប្រឌិត និងបង្កើតបំណិនអស់មួយជីវិត។ សិស្សនៃរដ្ឋ Western Australia ទទួលលទ្ធផលល្អជាងកម្រិតមធ្យមរបស់អន្តរជាតិជាប់ជានិច្ច ដូចដែលវាយតម្លៃដោយកម្មវិធីសម្រាប់ការវាយតម្លៃសិស្សអន្តរជាតិ (PISA)។ កម្មវិធីសិក្សានេះផ្តល់សាលាបឋមសិក្សារយៈពេល7ឆ្នាំ (មុនបឋមសិក្សាដល់ថ្នាក់ទី 6) និងសាលាមធ្យមសិក្សារយៈពេល6ឆ្នាំ (ថ្នាក់ទី7 ដល់ទី12) ដោយរៀបចំសិស្សសម្រាប់ការឆ្លងកាត់ចូលទៅកាន់សាកលវិទ្យាល័យ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬអាជីពក្នុងពិភពលោក។

សិស្សអន្តរជាតិអាចទទួលជំនួយភាសាអង់គ្លេសតាមរយៈកម្មវិធីភាសាអង់គ្លេសដែលរៀបចំសម្រាប់បុគ្គលដោយឡែក ហើយដែលបង្ហាត់ដោយបុគ្គលិកមានឯកទេស ដោយមានរួមទាំងសិស្សដែលស្ថិតនៅក្នុងដំណាក់កាលដំបូងទាំងឡាយនៃការសិក្សាភាសាអង់គ្លេស។

សិស្សជាង 90% ទទួលសញ្ញាបត្រសិក្សាអប់រំរដ្ឋ Western Australia (WACE)។ ការសិក្សាអប់រំរបស់អូស្ត្រាលីត្រូវបានទទួលស្គាល់និងគោរពដោយសាកលវិទ្យាល័យកំពូលទាំងឡាយនៅទូទាំងពិភពលោក។ ហេតុការណ៍នេះធានាថា សិស្សដែលបានបញ្ចប់ការសិក្សាត្រូវបានរៀបចំយ៉ាងល្អសម្រាប់ការសិក្សាថ្នាក់កាន់តែខ្ពស់ ទោះជាគេជ្រើសយកការសិក្សានៅប្រទេសអូស្ត្រាលីឬទីកន្លែងឯទៀតក៏ដោយ។





## តម្លៃសមរម្យ

ការសិក្សានៅក្នុងរដ្ឋ Western Australia មានតម្លៃសមរម្យ ដោយមានថ្លៃឈ្នួលបង្ហាត់បង្រៀនសមហេតុផល ហើយប្រាក់ដុល្លារអូស្ត្រាលីផ្តល់នូវតម្លៃដ៏ល្អក្រៃលែងបើប្រៀបធៀបនឹងប្រាក់ដុល្លារអាមេរិកឬប្រាក់ផោនអង់គ្លេស។ ហេតុការណ៍នេះធ្វើឲ្យទីក្រុង Perth ជាជម្រើសកំពូលមួយសម្រាប់សិស្សមកពីប្រទេសកម្ពុជា ដែលស្វែងរកការសិក្សាអប់រំមានគុណភាពនិងតម្លៃសមរម្យ។

## ជម្រើសមុខវិជ្ជានិងកម្មវិធីឯកទេស

សិស្សក្នុងសាលារៀនរបស់យើងអាចជ្រើសយកចេញពីមុខវិជ្ជាសិក្សាចំនួនយ៉ាងច្រើនផ្សេងៗគ្នា ដោយមានរួមទាំងវិទ្យាសាស្ត្រ មនុស្សសាស្ត្រ អង់គ្លេស និងគណិតសាស្ត្រ។ ហួសពីមុខវិជ្ជាគ្រឹះទាំងនេះ សិស្សមានលទ្ធភាពទទួលកម្មវិធីឯកទេសក្នុងផ្នែក STEM កម្មវិធីពង្រីកការសិក្សា កីឡា តន្ត្រី និងសិល្បៈ ដោយអនុញ្ញាតឲ្យសិស្សបន្តស្វែងរកទៅតាមចំណាប់អារម្មណ៍របស់ខ្លួន កសាងបំណិនផ្សេងៗគ្នា និងធ្វើឲ្យល្អប្រសើរនៅក្នុងផ្នែកដែលគេចង់បានជាខ្លាំង។

## ការស្នាក់នៅតាមផ្ទះគ្រួសារ និងទីលំនៅ

សិស្សមានជម្រើសក្នុងការស្នាក់នៅជាមួយផ្ទះគ្រួសារផ្តល់ទីកន្លែងឲ្យស្នាក់នៅដែលត្រូវបានជ្រើសរើសដោយប្រុងប្រយ័ត្ន ហើយដែលផ្តល់មជ្ឈដ្ឋានទីលំនៅទទួលស្វាគមន៍និងមានសុវត្ថិភាព ដែលបង្កើនការយល់ដឹងអំពីពហុវប្បធម៌និងបំណិនភាសា។ កម្មវិធីស្នាក់នៅតាមផ្ទះគ្រួសារផ្តល់ឲ្យសិស្សនូវមជ្ឈដ្ឋានទីលំនៅដែលអប់រំប្រដែប្រដៅនិងមានសុវត្ថិភាព ដែលអាចឲ្យសិស្សទទួលបទពិសោធន៍វប្បធម៌អូស្ត្រាលីពិតប្រាកដ។ ការរស់នៅជាមួយគ្រួសារដែលទទួលឲ្យស្នាក់នៅជួយសិស្សកែលំអអង់គ្លេសរបស់គេ កសាងការតភ្ជាប់អស់មួយជីវិត និងឲ្យខ្លួនគេលាយចូលទៅក្នុងសហគមន៍គាំទ្រមួយ។ សិស្សក៏អាចជ្រើសយកការរស់នៅជាមួយអាណាព្យាបាលម្នាក់ផងដែរ។ បុគ្គលនេះត្រូវតែជាមាតាឬបិតា ឬសាច់ញាតិជិតស្និទ្ធ ដែលមានអាយុចាប់ពី21ឆ្នាំឡើងទៅ ដែលត្រូវបានយល់ព្រមតាមរយៈ Department of Home Affairs (ក្រសួងកិច្ចការមហាផ្ទៃ)។







ដឹងថែមទៀតអំពីការសិក្សានៅក្នុងរដ្ឋ Western Australia ដោយចូលទៅកាន់វ៉ិបសៃ schoolsinternational.wa.gov.au.

**Department of Education**
CRICOS Provider Code: 01723A